ប្រការ ២ : អ្នកស្រី មាស សុផល ត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផលទឹកត្រីឆ្ងាញ់ សញ្ញា «ផ្កាយបី» និងទឹកស៊ីអ៊ីវសញ្ញា «ជ័យជំនះ» ស្របតាមគំរូសញ្ញាសំគាល់ ដែល បានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវ ធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើស ច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះ នឹងត្រូវដកហូតវិញ ដោយគ្មានសំណងឡើយ ។

* * *

ប្រកាស លេខ ៦៩៣ ផក.ប្រក ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី អ៊ូ កូឡាយ ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០០៨៤៤៩ ក.ណ ចុះថ្ងៃទី ១៦-០១-៨៥ អាស័យដ្ឋានបច្ចុប្បន្ន ភូមិព្រែករទាំងឃុំ ព្រែកកំពិស ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាលបន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៤០សេះ នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : អ្នកស្រី អ៊ូ កូឡាប ត្រូវបន្តដំណើរការផលិតកម្ម_អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះ នឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាស លេខ ៦៩៤ ផក.ប្រក ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក ទិត គីន ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ១៤២១៧៥ ក.ធ ចុះថ្ងៃទី ២៣-៤-៩២ អាស័យដ្ឋានបច្ចុប្បន្ន ភូមិធ្នុកទ្រូ ឃុំធ្នុកទ្រូ ស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង បង្កើនបន្ថែមបរិមាណផលិតទឹកកកដើម នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : ប្រកាសលេខ ១៧៧៦ ផក.ប្រក ចុះថ្ងៃទី ០៩_១២_៩៤ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវបានចាត់ទុកជាមោឃៈចាប់តាំងពីថ្ងៃដែលបានចុះហត្ថលេខាលើប្រកាសនេះ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះ នឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាស លេខ ៦៩៥ ផក.ប្រក ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក ប៊ិត ប៊ុន ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២៣៧០៣២ ស.រ ចុះថ្ងៃទី ១៦_១១_៩៣ អាស័យដ្ឋានបច្ចុប្បន្ន ភូមិសាលាកំរើក ឃុំសាលាកំរើក ស្រុកសៀមរាប ខេត្តសៀមរាប បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៧៥សេះ នៅក្នុងទីតាំងភូមិជ្រាវ ឃុំជ្រាវ ស្រុកសៀមរាប ខេត្តសៀមរាប ។

ប្រការ ២ : លោក ប៊ិត ប៊ុន ត្រូវបន្តដំណើរការផលិត_អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ភាគរយ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះ នឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ហត្ថលេខា និង ត្រា

ពូ សុធីរៈ

* * *

ប្រកាស លេខ ៧០១ ផក.ប្រក ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក ឃុន សំបូរ ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០០២៧៤១ក.ច ចុះថ្ងៃទី ២០–៧–៨៥ អាស័យដ្ឋានបច្ចុប្បន្ន ភូមិទី ៣ ឃុំវាលវង់ ស្រុកកំពង់ចាម ខេត្តកំពង់ចាម បន្តដំណើរការរោងម៉ាស៊ីនថាមពលអគ្គិសនី ដោយប្រើម៉ាស៊ីនចំនួន ២គ្រឿង មានអនុភាពសរុប ១២៥ គីឡូវ៉ាត់ នៅក្នុងទីតាំង ភូមិពៃទឹង ឃុំជ្រៃវៀន ស្រុកព្រៃឈរ ខេត្តកំពង់ចាម ។

ប្រការ ២ : បកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើស

ច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះ នឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ជ.រដ្ឋមន្ត្រី

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

អ៊ិត ប្រាំង

* * *

២_ទីស្តីការរដ្ឋមន្ត្រីក្រសួងព័ត៌មាន

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ១៩៩៦

ប្រកាស លេខ ៣១២/៩៦ ពម.ប្រក

អនុញ្ញាតអោយបោះពុម្ពផ្សាយបន្ថែមកាសែត «CAMRODIA TODAY »

ជាភាសាខ្មែរមានឈ្មោះ « កម្ពុជាថ្ងៃនេះ»

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ជំពូក ៣ មាត្រាទី៤១
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ស្តីពីរបបសារព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើដោយតាមព្រះរាជក្រមលេខ ន.សរក.ម ០៨៩៥-០៧ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥
- បានឃើញសំណើសុំចេញផ្សាយបន្ថែមសារព័ត៌មាន Cambodia Today ជាភាសាខ្មែរមានឈ្មោះ «កម្ពុជាថ្ងៃនេះ » ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦

សំរេច

ប្រការ ១ : អនុញ្ញាតអោយបោះពុម្ពផ្សាយបន្ថែមកាសែត « Cambodia Today » ជាភាសាខ្មែរមានឈ្មោះ «កម្ពុជាថ្ងៃនេះ » ដំណើរការចែក ផ្សាយដោយមានលោកចូ ស៊ីងគួ

ជាចាងហ្វាងការផ្សាយ ។ ទីស្នាក់ ការលេខ ១៧៩ BE0 ផ្លូវលេខ ៦៣ភ្នំពេញ ។ ក្នុងករណីមានការផ្លាស់ប្តូរនូវចំណុចណាមួយក្នុងអត្តសញ្ញាណ នៃសារពតិមានរបស់ខ្លួនត្រូវជូនដំណឹងជាមុន ០៥ថ្ងៃ មកក្រសួងពតិមានដើម្បីរង់ចាំសេចក្តីសំរេចជាថ្មី ។

ប្រការ ២ : រាល់ដំណើរការបោះពុម្ពចែកផ្សាយត្រូវគោរពតាមគោលការណ៍ក្រមសីលធមិ អ្នកពតិមានឈរលើស្មារតី ទទួលខុសត្រូវខ្ពស់ក្នុងវិជ្ជាជីវៈរបស់ខ្លួន ។ ខ្លឹមសារអត្ថបទត្រូវអនុវត្តន៍អោយបានសមស្របតាមទំនៀមទំលាប់ប្រពៃណីល្អ និង ច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា រួចស្នើប្រគល់កាសែតចំនួន ៦ច្បាប់ រៀងរាល់លេខចេញផ្សាយមកតំកល់ទុកជាឯកសារ នៅក្រសួងពតិមាន ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តល្មើសអំពីសេចក្តីដូចមានចែងក្នុងប្រការ១ និងប្រការ ២ ខាងលើនេះសាម៉ីខ្លួនត្រូវទទួល ទោសតាមច្បាប់ជាធរមាន ។

ប្រការ ៤ : អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុប្រធាននាយកដ្ឋានមណ្ឌលពតិមាន នៃក្រសួងពតិមាន និងចាងហ្វាងការ ផ្សាយកាសែត « Cambodia Today » ត្រូវអនុវត្តន៍នូវប្រកាសនេះ ។

ប្រការ ៥ : ប្រកាសនេះ មានប្រសិទ្ធភាពរយៈពេល ២ឆ្នាំ និងចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ជ. រដ្ឋមន្ត្រី

រដ្ឋលេខាធិការ

ខៀវ កាញារីទ្ធ

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ១៩៩៦

ប្រកាស លេខ ៣១៣/៩៦ ពម.ប្រក

អនុញ្ញាតអោយផ្ទេរសិទ្ធិចាងហ្វាងការផ្សាយកាសែតអន្តរបុរី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ជំពូក ៣ មាត្រា ទី៤១
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញច្បាប់ស្តីពីរបបសារពត៌មាន នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើតាមព្រះរាជ ក្រមលេខ ន.ស/រ ក.ម ០៨៩៤-០៧ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥
- បានឃើញសំណើ ចុះថ្ងៃទី១១ ខែ តុលា ឆ្នាំ ១៩៩៦ សុំប្តូរចាងហ្វាងការផ្សាយរបស់កាសែត «អង្គរបុរី» ពីលោក មុត សាម៉េត មកលោក ជួត សាដែត វិញ

សំរេច

ប្រការ ១ : អនុញ្ញាតអោយផ្ទេរសិទ្ធិចាងហ្វាងការផ្សាយកាសែត « អង្គរបុរី » ពីលោក មុត សាម៉េតមកលោក ហួរ សាដែត ហៅ ជួត សាដែត វិញ ។ ទីស្នាក់ការផ្ទះ លេខ ៨៩៦E2 ផ្លូវកម្ពុជាក្រោម សង្កាត់ទឹក ល្អក់ ១ ខ័ណ្ឌទួលគោក ក្រុងភ្នំពេញ ។

ក្នុងករណីមានការផ្លាស់ប្តូរនូវចំណុចណាមួយក្នុងអត្តសញ្ញាណនៃសារពត៌មានរបស់ខ្លួនត្រូវជូនដំណឹងជា មុន ៥ថ្ងៃមកក្រសួងពត៌មាន ដើម្បីរង់ចាំសេចក្តីសំរេចជាថ្មី ។

ប្រការ ២ : រាល់ដំណើរការបោះពុម្ពចែកផ្សាយត្រូវគោរពតាមគោលការណ៍ក្រមសីលធម៌ អ្នកកាសែត និងឈរលើ ស្មារតីទទួលខុសត្រូវខ្ពស់ ក្នុងវិជ្ជាជីវៈរបស់ខ្លួន ។ ខ្លឹមសារអត្ថបទត្រូវអនុវត្តន៍អោយបានសមស្របតាម ទំនៀមទំលាប់ ប្រពៃណីល្អនិងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា រួចស្នើប្រគល់កាសែតចំនួន ០៦ច្បាប់ រៀងរាល់លេខចេញផ្សាយមកតំកល់ទុកជាឯកសារ នៅក្រសួងពត៌មាន ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តិល្មើស អំពីសេចក្តីដូចមានចែងក្នុងប្រការ ០១ ប្រការ ០២ ខាងលើនេះ សាមីខ្លួនត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៤ : អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានមណ្ឌលពត៌មាន នៃក្រសួងពត៌មាន និងចាងហ្វាង កាសែត « អង្គរបុរី » ត្រូវអនុវត្តន៍នូវប្រកាសនេះ ។

ប្រការ ៥ : ប្រកាសនេះ មានប្រសិទ្ធភាពរយៈពេល ២ ឆ្នាំ និងចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

ខៀវ កាញារីទ្ធ

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ១៩៩៦

ប្រកាសលេខ ៣១៤/៩៦ ពម.ប្រក

អនុញ្ញាតអោយប្តូរឈ្មោះសារពត៌មាន «សកលមកជា»

សាធារណមតិ

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ជំពូក ៣ មាត្រាទី៤១
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ស្តីពីរបបសារពត៌មាន នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើតាមព្រះរាជ ក្រមលេខ ន.សរ ក.ម ០៨៩៥-០៧ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥
- បានឃើញសំណើ ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦ ស្តីពីការសុំប្តូរឈ្មោះសារមានពី « សកល » មក ជា « សាធារណមតិ » វិញ

សំរេច

ប្រការ ១ : អនុញ្ញាត្តិអោយប្តូរឈ្មោះសារពត៌ « កសល » មកជា « សាធារណមតិ » បោះពុម្ពចែកផ្សាយដោយមាន លោក ឡាច សំរោង ជាចាងហ្វាងការផ្សាយ ។ ទីស្នាក់ការ ផ្ទះលេខ ៩៤ ផ្លូវសហភាពសូវៀត ។

ក្នុងករណីមានការផ្លាស់ប្តូរនូវចំណុចណាមួយក្នុងអត្តសញ្ញាណ នៃសារពត៌មានរបស់ខ្លួនត្រូវជូនដំណឹង មុន ០៥ថ្ងៃ មកក្រសួងពត៌មាន ដើម្បីរង់ចាំសេចក្តីសំរេចជាថ្មី ។

ប្រការ ២ : រាល់ដំណើរការបោះពុម្ពចែកផ្សាយត្រូវគោរពតាមគោលការណ៍ក្រមសីលធម៌ អ្នកសារពត៌មានឈរលើ ស្មារតីទទួលខុសត្រូវខ្ពស់ក្នុងវិជ្ជាជីវៈរបស់ខ្លួន ។ ខ្លឹមសារអត្ថបទត្រូវអនុវត្តន៍អោយបានសមស្របតាមទំនៀមទំលាប់ប្រពៃណីល្អ និងច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា រួចស្នើប្រគល់សារពត៌មានចំនួន ៦ច្បាប់ រៀងរាល់លេខចេញផ្សាយមកតំកល់ទុកជាឯកសារនៅក្រសួងពត៌មាន ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តល្មើសអំពីសេចក្ដីដូចមានចែងក្នុងប្រការ ១ និងប្រការ ២ ខាងលើនេះសាមីខ្លួនត្រូវ ទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៤ : អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានមណ្ឌលពត៌មាន នៃក្រសួងពត៌មាន និងចាងហ្វាង កាសែត « សាធារណមតិ » ត្រូវអនុវត្តន៍នូវប្រកាសនេះ ។

ប្រការ ៥ : ប្រកាសនេះមានប្រសិទ្ធភាពរយៈពេល ២ ឆ្នាំ និងចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

ខៀវ កាញារីទ្ធ

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ១៩៩៦

ប្រកាសលេខ ៣១៩/៩៦ ពម. ប្រក

ទទួលស្គាល់លោក ZHU.CHANGDU ជាប្រធាន

ការិយាល័យ នៃទីភ្នាក់ងារសារពត៌មាន XIN HUA

ជំនួសលោក YANG UING

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ មករា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ស្ដីពីរបបសារពត៌មាន នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើតាមព្រះរាជ ក្រមលេខ ន.សរ ក.ម ០៨៩៥–០៧ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥
- បានឃើញលិខិតសុំផ្លាស់ប្ដូរអ្នកយកពត៌មានរបស់លោក GUO CHAOREN ជាអគ្គនិពន្ធនាយក នៃទី ភ្នាក់ងារចិន XINHUA ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ១៩៩៦

សំរេច

ប្រការ ១ : ទទួលស្គាល់លោក ZHU CHANGDU ជាប្រធានការិយាល័យនៃទីភ្នាក់ងារសារពត៌មាន XIN HUA ប្រចាំនៃ ព្រះរាជាណាចក្រកម្ពុជាជំនួសលោក YANG MING ដែលនឹងត្រូវចប់អាណត្តិ ។

ប្រការ ២ : ខ្លឹមសារ និងសកម្មភាពផ្សព្វផ្សាយពត៌មាន ត្រូវឈរលើស្មារតីទទួលខុសត្រូវខ្ពស់ គោរពតាមក្រមសីលធម៌ វិជ្ជាជីវៈអ្នកសារពត៌មាន និងច្បាប់នៃព្រះរាជាណាចក្រកម្ពុជាព្រមទាំងសហការជាមួយនាយកដ្ឋានមណ្ឌលពត៌មាន ។

ប្រការ ៣ : អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានមណ្ឌលពត៌មាន នៃក្រសួងពត៌មាន និងលោកZHU CHANGDU ត្រូវអនុវត្តន៍នូវប្រកាសនេះ ។

ប្រការ ៤ : ប្រកាសនេះ មានប្រសិទ្ធភាពរយៈពេល ៣ ឆ្នាំ និងចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

អៀង មូលី

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ១៩៩៦

ប្រកាសលេខ ៣២១/៩៦ ពម.បល.ប្រក

ស្តីពីការតែងតាំង មន្ត្រីរាជការ

* * *

រដ្ឋមន្ត្រី ក្រសួង ពត៌មាន

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២នស.៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ១៩៩៤ ស្តីពីការរៀបចំ និងការ ប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

- បានឃើញ ព្រះរាជក្រម នសរកម.០១៩៦.១៤ ចុះថ្ងៃទី ២៤ ខែ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួង ពតិមាន ,
- បានឃើញ លិខិតលេខ ៣១៤៨ លស ចុះថ្ងៃទី ១២ ខែ កញ្ញា ១៩៩៦ របស់ប្រតិភូរាជរដ្ឋាភិបាលប្រចាំ រាជធានីភ្នំពេញ
- យោងតាមការចាំបាច់
- ពិនិត្យលើលក្ខណៈសម្បត្តិ និងសមត្ថភាពមន្ត្រីរាជការ ។

សំរេច

ប្រការ ១ : តែងតាំងលោក យោគ ឈា ជាប្រធានមន្ទីរពតិមានរាជធានីភ្នំពេញ នៃក្រសួង ពតិមាន ។

ប្រការ ២ : ឯកឧត្តម អគ្គនាយករដ្ឋបាល ហិរញ្ញវត្ថុ លោកនាយកខុទ្ទកាល័យ បណ្តាអគ្គនាយកដ្ឋានចំណុះ លោក ប្រធាននាយកដ្ឋានរដ្ឋបាល បុគ្គលិក លោកប្រធាននាយកដ្ឋានផែនការ គណនេយ្យ មន្ទីរពតិមាន រាជធានីភ្នំពេញ គ្រប់មន្ទីរពតិមានខេត្ត ក្រុង និងសាមីខ្លួនត្រូវអនុវត្តន៍ប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

អៀង មូលី

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ១៩៩៦

សេចក្តីសំរេចលេខ ៣២២/៩៦ ពម.សសរ

ស្តីពីការសំរេចផ្អាកការចេញផ្សាយសារពតិមាន

« អ្នកប្រយុទ្ធ »

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ជំពូកអវសានប្បញ្ញត្តិ មាត្រាទី ១៣៩
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ វរ្ម័នព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា

- បានឃើញច្បាប់ស្ដីពីរបបសារពត៌មាន នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើតាមព្រះ រាជក្រមលេខ ន.ស/ រ ក.ម ០៨៩៥-០៧ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥
- បានឃើញប្រកាសរបស់ក្រសួងពត៌មានលេខ ២៦៨/៩៥ ពមប្រក ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការអនុញ្ញាតអោយសារពត៌មានឈ្មោះ « អ្នកប្រយុទ្ធ » ចេញផ្សាយដែលមានលោក សំ វុឌ្ឍី ជា ចាងហ្វាងការផ្សាយ

សំរេច

ប្រការ ១ : ដោយឃើញថា សារពត៌មាន « អ្នកប្រយុទ្ធ » ចេញផ្សាយឆ្នាំទី២លេខ ១០៦ ថ្ងៃស្រុក សៅរ៍ទី ១៣-១៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលចុះផ្សាយអត្ថបទមួយក្រោមចំណងជើងថា « លោក ហ៊ុន សែន អន់ជាងឆ្កែ » ជាអត្ថបទមួយដែលមានចរិតជេរប្រមាថ ធ្វើអោយប៉ះពាល់ដល់កិត្តិយស និងសេចក្ដីថ្លៃថ្នូររបស់អ្នកដទៃ ដូចមានចែងក្នុងច្បាប់ ស្ដីពីរបបសារពត៌មានត្រង់ជំពូកទី២ មាត្រាទី១០ និងប្រាសចាកពីក្រមសីលធម៌ អ្នកសារពត៌មាន ក្រសួងពត៌មានសំរេចផ្អាកការចេញផ្សាយរបស់សារពត៌មាន « អ្នកប្រយុទ្ធ » រយៈពេល ២០ថ្ងៃ ចាប់ពីថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដល់ថ្ងៃទី ៣ ខែ មករា ឆ្នាំ ១៩៩៧ ទុកជាការព្រមាន ។

ប្រការ ២ : អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានមណ្ឌលពត៌មាននៃក្រសួងពត៌មាននិងលោក សំ វុឌ្ឍី ចាងហ្វាងការផ្សាយត្រូវអនុវត្តន៍នូវសេចក្ដីសំរេចនេះតាមភារកិច្ចរបស់ខ្លួន ។

ប្រការ ៣ : សេចក្ដីសំរេចនេះ ចូលជាធរមានចាប់ពីថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ១៩៩៦ នេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

ខៀវ កាញារីទ្ធ

* * *

៣_ទីស្ដីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ១៩៩៦

ប្រកាសលេខ ៣៤៩ ពណគន.ប្រក

ស្ដីពីការប្រគល់ទីតាំងដី និងសំបកឃ្លាំងនៅក្រុងព្រះសីហនុ

រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តមសីហនុវរ្ម័ន** ព្រះមហាក្សត្រនៃ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តមសីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញកំណត់ហេតុប្រគល់ ទទួលទីតាំងដីនិងសំបកឃ្លាំងលើ « ក្រុងព្រះសីហនុ » ចុះថ្ងៃទី ០២/ ១២/៩៦

សំរេច

ប្រការ ១ : ប្រគល់ការគ្រប់គ្រងទីតាំងដីនិងសំបកឃ្លាំង ដែលមានផ្ទៃដីសរុប ៦.៣៦២ ម² ក្នុងនោះឃ្លាំងមាន បណ្ដោយ ៣៦ ម ទទឹង ២៨ ម កំពស់ ៤ ម ស្ថិតនៅឃ្លាំងលើផ្លូវជាតិលេខ ៤ ក្រុងព្រះសីហនុ ជូន ទៅលោក ឈិត មាន ជាអ្នកគ្រប់គ្រងផ្ទាល់ ដោយផ្ដាច់ចេញពីការគ្រប់គ្រងរបស់ក្រុមហ៊ុនកសិផលរុក្ខផល ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ប្រការ ២ : លោក ឈិត មាន ត្រូវគោរពនិងអនុវត្តអោយបាននូវរាល់ប្រការផ្សេងៗ នៃច្បាប់របស់រដ្ឋដើម្បីធានាដល់ សុវត្ថិភាពនិងបរិដ្ឋានសង្គម ។

ប្រការ ៣ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធានក្រុមហ៊ុន កសិផល រុក្ខផល ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ អោយទទួលបានលទ្ធផលល្អប្រសើរចាប់ពីថ្ងៃចុះ ហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ចម ប្រសិទ្ធ

* * *

៤_ទីស្តីការរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

សេចក្តីសំរេច

រាជធានីភ្នំពេញ , ថ្ងៃទី ៦ ខែ ធ្នូ ឆ្នាំ ១៩៩៦

សេចក្តីសំរេចលេខ ៤១៨ សសរ.សក

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន

* * *

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១–១១–១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
– បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ១០៩៤/៩០ ចុះថ្ងៃទី ៣១–១០–១៩៩៤ ស្តីពីការកែសំរួល សមាសភាព រាជរដ្ឋាភិបាលកម្ពុជា
– យោងតាមតម្រូវការចាំបាច់របស់ក្រសួង

សំរេច

ប្រការ ១ : ឯកឧត្តម ឃី តាំងលឹម អនុប្រធានទី ២ គណកម្មាធិការជាតិទន្លេមេគង្គ និងជាសមាជិកគណកម្មការរួម នៃ ទន្លេមេគង្គ ត្រូវចាត់អោយទទួលបន្ទុកការងារ សិក្សាស្រាវជ្រាវផែនទីព្រះរាជាណាចក្រកម្ពុជា បន្ថែមលើភារកិច្ចបច្ចុប្បន្ន ។

ប្រការ ២ : ឯកឧត្តម ឃី តាំងលីម ត្រូវចាត់ជាតំណាង ក្រសួងសាធារណការ និងដឹកជញ្ជូន ក្នុងកិច្ចសហការជាមួយក្រុមជំនាញការ JICA នៃប្រទេសជប៉ុន ដើម្បីសិក្សាស្រាវជ្រាវក្នុងគំរោងស្តារ និងកសាងព្រះរាជាណាចក្រកម្ពុជា (Reconnaissance survey project of anemetgency fehabilitafion anb teconstruction of Kingdom of Cambodia) ។

ប្រការ ៣ : លោកនាយកខុទ្ទកាល័យក្រសួងសាធារណការ និងដឹកជញ្ជូន និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តរៀងៗខ្លួន តាមខ្លឹមសារនៃសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន
ហត្ថលេខា និងត្រា
អ៊ឹង ហ៊ួត

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ១៩៩៦

ប្រកាសលេខ ៤៤៧ ប្រក.សក.ប

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១–១១–១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១–១០–១៩៩៤ ស្តីពីការកែសំរួល សមាសភាព រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦.០៣ ចុះថ្ងៃទី ២៤–០១–១៩៩៦ ស្តីពីការបង្កើតក្រសួង សធារណការ និងដឹកជញ្ជូន
- យោងតាមការចាំបាច់របស់ក្រសួង

សំរេច

ប្រការ ១ : លោក សោម សារី ត្រូវចាត់តាំងជាទីប្រឹក្សាអម ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន ។

ប្រការ ៣ : លោកនាយកខុទ្ទកាល័យក្រសួងសាធារណការនិងដឹកជញ្ជូននិងសាម៉ីខ្លួន ត្រូវទទួលបន្ទុកអនុវត្តរៀងៗខ្លួន តាមខ្លឹមសារ នៃប្រកាសនេះ ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន
ហត្ថលេខា និងត្រា
អ៊ុង ហឿត

* * *

៥_ទីស្តីការរដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ១៩៩៦

ប្រកាសលេខ ៦១៣ ប្រក.កសក.ចត

ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤–៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការ កែសំរួលសមាសភាពរាជរដ្ឋាភិបាល

- បានឃើញព្រះរាជក្រមលេខ នស.រកម ០១៩៦.១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការ បង្កើត ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ នស.រកម ០១៩៦.១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ របស់រាជរដ្ឋាភិបាល ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- យោងតាមតំរូវការរៀបចំគ្រប់គ្រង និងការប្រព្រឹត្តទៅរបស់ខុទ្ទកាល័យរដ្ឋមន្ត្រី ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ។

សំរេច

ប្រការ ១ : ត្រូវបានតែងតាំងក្រុមខុទ្ទកាល័យ ០១ក្រុមជាជំនួយការជូនឯកឧត្តមរដ្ឋមន្ត្រីដូចមានរាយនាមខាងក្រោម ÷

-លោក **ឡុន ទ៉ាត** ជានាយកខុទ្ទកាល័យ បន្ថែមលើមុខងារសព្វថ្ងៃជាទីប្រឹក្សា

-លោក **អ៊ឹង គីមសេង** ជានាយខុទ្ទកាល័យ

-លោក **សុខ ស៊ីឡូ** ជាលេខាធិការផ្ទាល់

ប្រការ ២ : អគ្គនាយកក្រសួង ប្រធានមន្ទីរ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានគណនេយ្យហិរញ្ញវត្ថុ ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួង និង សាមីជន ត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងខ្លួនៗ ចាប់ពីថ្ងៃដែលចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

តាវ សេងហួរ

* * *

៦_ទីស្តីការរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ០៩ ខែ មករា ឆ្នាំ ១៩៩៧

ប្រកាសលេខ ២២៥ ប្រក.វវសបុ ស្តីពី

ការទទួលស្គាល់លទ្ធផលនៃការប្រឡងយក

បរិញ្ញាបត្រសិល្បៈផ្នែកស្ថាបត្យកម្ម និងនគរោបនីយវិទ្យា

ជំនាន់ទី ១ ឆ្នាំសិក្សា ១៩៩៤—៩៥

* * *

រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស.រកម.០១៩៦.០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញលិខិតលេខ ១៤២ សាភវស.អស.សណ ២៦ ខែ កញ្ញា ឆ្នាំ ១៩៩៦ របស់សាកលវិទ្យាល័យ ភូមិន្ទវិចិត្រសិល្បៈ ស្តីពីការសុំប្រកាសទទួលស្គាល់និស្សិតចំនួន ១៣៦ នាក់ ដែលបានទទួលបរិញ្ញាប័ត្រផ្នែកស្ថាបត្យកម្ម និង នគរោបនីយវិទ្យា ក្នុងឆ្នាំសិក្សា ១៩៩៤—៩៥

សំរេច

ប្រការ ១ : ទទួលស្គាល់ថា បានប្រឡងជាប់បរិញ្ញាប័ត្រ ផ្នែកស្ថាបត្យកម្ម និងនគរោបនីយវិទ្យា ជាស្ថាពរនាសម័យប្រឡង ថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ១៩៩៥ និស្សិតចំនួន ១៣៦នាក់ ។

ល.រ	លេខតុ	គោត្តនាម និង នាម	ភេទ	ថ្ងៃ.ខែ.ឆ្នាំកំណើត	និទ្ទេស
១	១	ហ៊ុ ចិន្តា	ប្រុស	០៧.១.១៩៦៩	ល្អណាស់
២	២	ទុំ ធនី	ប្រុស	០១.២.១៩៧០	ល្អណាស់
៣	៣	ប៊ុន លី	ប្រុស	១០.១.១៩៦៩	ល្អណាស់
៤	៤	ប៊ិល ផារ៉ារិទ្ធ	ប្រុស	១៧.៦.១៩៧០	ល្អណាស់
៥	៥	ប៉ែន សុផល	ប្រុស	០៥.៤.១៩៧០	ល្អណាស់
៦	៦	អន ស៊ីថន	ប្រុស	០៩.១១.១៩៦៦	ល្អណាស់
៧	៧	សៅ ភាត្រា	ប្រុស	១៥.៨.១៩៦៧	ល្អណាស់
៨	៨	អេង វណ្ណា	ប្រុស	១៦.១០.១៩៦៥	ល្អណាស់
៩	៩	គ្រៀល ស៊ីណា	ប្រុស	១០.៣.១៩៦៩	ល្អណាស់
១០	១០	ភ៉ា ម៉ូរិន	ប្រុស	០២.៩.១៩៥៥	ល្អណាស់
១១	១១	ឡឹក សារ៉េត	ប្រុស	០៤.៤.១៩៦០	ល្អណាស់
១២	១២	ឡៅ ទិព្វសីហា	ប្រុស	១៥.៨.១៩៧១	ល្អណាស់
១៣	១៣	គ្រេត វិសាលលក្ខា	ប្រុស	០៥.២.១៩៦៩	ល្អណាស់
១៤	១៤	ទិត ខេមរា	ប្រុស	១៥_៧_១៩៧០	ល្អណាស់
១៥	១៥	អ៊ិន សុផល	ប្រុស	០៤_៣_១៩៦៩	ល្អណាស់
១៦	១៦	ហង្ស ភីរក្ស	ប្រុស	០២–៦–១៩៧១	ល្អណាស់
១៧	១៧	ចំរើន កត្តិកា	ស្រី	០៩–៧–១៩៧០	ល្អណាស់
១៨	១៨	ឈន សេដ្ឋា	ប្រុស	១៣–១១–១៩៧១	ល្អណាស់
១៩	១៩	ច្រាក់ បូចារី	ស្រី	០៥–១០–១៩៦៩	ល្អណាស់
២០	២០	ម៉េង ហ៊ាង	ប្រុស	១៥–៥–១៩៧២	ល្អណាស់
២១	២១	ជុំ វុឌ្ឍី	ប្រុស	២១–២–១៩៧១	ល្អណាស់
២២	២២	ឈឹម ចំរើន	ប្រុស	១០–១១–១៩៧១	ល្អណាស់
២៣	២៣	គួច សុផានំណាក់	ប្រុស	១០–៥–១៩៧២	ល្អណាស់
២៤	២៤	ប៊ុង ផារិទ្ធ	ប្រុស	១៨–១០–១៩៧១	ល្អណាស់

២៥	២៥	តូ សុចន្ទថុល	ប្រុស	១២-២-១៩៧១	ល្អណាស់
២៦	២៦	កែវ សារ៉ែន	ប្រុស	០៧-៦-១៩៦៨	ល្អណាស់
២៧	២៧	អេន ចន្ទដារិន	ប្រុស	១៣-៤-១៩៦៨	ល្អណាស់
២៨	២៨	ផិត វ៉េណូ	ប្រុស	០៦-១០-១៩៦៤	ល្អណាស់
២៩	២៩	ប៉ែន ប៊ុនណ្ណារក្ស	ប្រុស	២៨-៥-១៩៦៩	ល្អណាស់
៣០	៣០	ផិន សុខម៉េង	ប្រុស	២៥-១០-១៩៦៨	ល្អណាស់
៣១	៣១	សុខ កាន់ណារិទ្ធ	ប្រុស	០៤-១០-១៩៦៧	ល្អណាស់
៣២	៣២	ធីន ចន្ទថន	ប្រុស	០៧-៥-១៩៧២	ល្អណាស់
៣៣	៣៣	ស៊ុន ប៊ុនរិទ្ធ	ប្រុស	០៤-៦-១៩៧០	ល្អណាស់
៣៤	៣៤	ស៊ី វុត្ថមុនី	ប្រុស	៣០-១២-១៩៦៩	ល្អណាស់
៣៥	៣៥	ហង្ស សុគតសំភារ	ប្រុស	០៥-៤-១៩៧២	ល្អ
៣៦	៣៦	ឥន្ទ សារិន	ប្រុស	២៤-៣-១៩៦៧	ល្អ
៣៧	៣៧	វង្ស វណ្ណា	ប្រុស	១៥-៥-១៩៧៣	ល្អ
៣៨	៣៨	ស្រេង ឃេង	ប្រុស	០៥-១-១៩៧០	ល្អ
៣៩	៣៩	ឆាន់ សុជាតិ	ប្រុស	០៩-៣-១៩៧០	ល្អ
៤០	៤០	ថៃ មករា	ប្រុស	០៩-១-១៩៧៣	ល្អ
៤១	៤១	ជា ចន្ទថៃបរ៉ាស់	ប្រុស	១០-១-១៩៧៣	ល្អ
៤២	៤២	និ វឌ្ឍនៈ	ប្រុស	០៥-៩-១៩៧០	ល្អ
៤៣	៤៣	សាន ញ៉ៀន	ប្រុស	០១-២-១៩៦៥	ល្អ
៤៤	៤៤	បេង ហុងសុជាតិសីលា	ប្រុស	០២-១១-១៩៧១	ល្អ
៤៥	៤៥	ប៊ុន ឡុង	ប្រុស	១៤-១២-១៩៦៩	ល្អ
៤៦	៤៦	ហាយ វណ្ណចន្ទ	ប្រុស	០៩-១១-១៩៧១	ល្អ
៤៧	៤៧	ឃឹម ចំរើន	ប្រុស	០៩-១០-១៩៧០	ល្អ
៤៨	៤៨	ហោ ប៊ុនលាំង	ប្រុស	១៥-១២-១៩៦៨	ល្អ
៤៩	៤៩	ភន សុមនា	ស្រី	១៨-១២-១៩៧០	ល្អ

៥០	៥០	ទៅ ព្រាង្គសុវណ្ណ	ប្រុស	២១-៦-១៩៧០	ល្អ
៥១	៥១	ចូវ សុទ្ធី	ប្រុស	២៣-៣-១៩៦៧	ល្អ
៥២	៥២	គង់ ប៉ូច	ប្រុស	២៩-១០-១៩៦៨	ល្អ
៥៣	៥៣	ប៉ែន សុវណ្ណរតនា	ប្រុស	០៨-៨-១៩៦៧	ល្អ
៥៤	៥៤	ណុប ប៉ូ	ប្រុស	១៧-៨-១៩៧១	ល្អ
៥៥	៥៥	ជា វណ្ណា	ប្រុស	០៥-១-១៩៧១	ល្អ
៥៦	៥៦	អ៊ុង បូណាហត្ថារ៉េច	ប្រុស	១៤-២-១៩៦៧	ល្អ
៥៧	៥៧	ហ៊ិន សុខេន	ប្រុស	១៥-១-១៩៦៨	ល្អ
៥៨	៥៨	អ៊ុក ស៊ីថា	ប្រុស	០៣-៤-១៩៦៩	ល្អ
៥៩	៥៩	ធីគុណ វិចិត្រ	ប្រុស	២៨-៨-១៩៧២	ល្អ
៦០	៦០	ថេង ស៊ីខ្សែម	ប្រុស	០៥-៣-១៩៦៨	ល្អ
៦១	៦១	សំ សុធារិទ្ធ	ប្រុស	០៨-៣-១៩៧០	ល្អ
៦២	៦២	តាន់ សុធារី	ស្រី	២៥-១២-១៩៧១	ល្អ
៦៣	៦៣	ឱ ឈុនហុក	ប្រុស	០៥-៥-១៩៧០	ល្អ
៦៤	៦៤	ហេង ពីកាណ្ណភក់	ប្រុស	១៤-៣-១៩៧២	ល្អ
៦៥	៦៥	ព្រំ គន្ធា	ស្រី	២០-៦-១៩៧០	ល្អ
៦៦	៦៦	តាន់ ម៉ាលី	ស្រី	១៦-២-១៩៦៩	ល្អ
៦៧	៦៧	សួស ធារ៉ា	ប្រុស	០៨-៤-១៩៧១	ល្អ
៦៨	៦៨	ថាច់ មនោរក្ស	ប្រុស	០២-៨-១៩៧១	ល្អ
៦៩	៦៩	ហេង ធូ	ប្រុស	០១-១-១៩៧១	ល្អ
៧០	៧០	ឈុន សោមា	ស្រី	០៦-៨-១៩៦៩	ល្អ
៧១	៧១	សំ គឹមហេង	ប្រុស	១៧-៤-១៩៦៦	ល្អ
៧២	៧២	ជាម ផល្លី	ស្រី	១០-៩-១៩៦៧	ល្អ
៧៣	៧៣	ម៉ក់ សម្បត្តិ	ប្រុស	១៣-១០-១៩៦៦	ល្អ
៧៤	៧៤	ភឹម ភិរុណ	ប្រុស	១៥-៤-១៩៦៩	ល្អ

៧៥	៧៥	ញ៉ែម ប៊ុនធឿន	ប្រុស	២៦-១២-១៩៦៤	ល្អ
៧៦	៧៦	ហេង សុខរិទ្ធី	ប្រុស	១២-៧-១៩៧០	ល្អ
៧៧	៧៧	ប៊ិន សម្បត្តិថារ័ត្ន	ប្រុស	១១-៣-១៩៧០	ល្អ
៧៨	៧៨	លឹម ទ្រី	ប្រុស	០៦-២-១៩៧០	ល្អ
៧៩	៧៩	ទ្រី ឆាយហុក	ប្រុស	០១-៦-១៩៦៩	ល្អ
៨០	៨០	ម៉ុក សាយសុវណ្ណា	ប្រុស	២៨-៤-១៩៧០	ល្អ
៨១	៨១	ប្រាក់ កេត	ប្រុស	១១-៨-១៩៦៣	ល្អ
៨២	៨២	មាន គីង	ប្រុស	០៦-៧-១៩៧០	ល្អ
៨៣	៨៣	អ៊ុក សីលា	ប្រុស	១០-១-១៩៦២	ល្អ
៨៤	៨៤	ម៉ោល ច័ន្ទតារា	ស្រី	១៦-៤-១៩៧០	ល្អ
៨៥	៨៥	សុខ ធី	ប្រុស	២៩-១១-១៩៧២	ល្អ
៨៦	៨៦	គង់ កុសល	ប្រុស	១៦-១០-១៩៧០	ល្អ
៨៧	៨៧	គាវ ប៊ុនធឿន	ប្រុស	០៤-៦-១៩៧៣	ល្អ
៨៨	៨៨	ណី ម៉ារឌី	ប្រុស	២០-១១-១៩៧០	ល្អ
៨៩	៨៩	ហេង វិទ្ធ	ប្រុស	០៧-៤-១៩៧៣	ល្អ
៩០	៩០	គី ឈាងភ៉ារី	ប្រុស	០១-១២-១៩៦៩	ល្អ
៩១	៩១	ប្រាក់ វឌ្ឍនា	ប្រុស	១០-២-១៩៧២	ល្អ
៩២	៩២	ភួន ភូម៉ូនីរតន៍	ប្រុស	០៥-១០-១៩៧២	ល្អ
៩៣	៩៣	ស្វ ណាសុត	ប្រុស	១០-១០-១៩៦៨	ល្អ
៩៤	៩៤	សុខ ផេងបូណា	ប្រុស	១៥-៤-១៩៧២	ល្អ
៩៥	៩៥	កុយ រតនន:បណ្ឌិត	ប្រុស	០២-១-១៩៧០	ល្អ
៩៦	៩៦	ឡុង សង្វា	ប្រុស	២១-៩-១៩៧០	ល្អ
៩៧	៩៧	ឃុន ភ៉ា	ប្រុស	២៥-២-១៩៦៤	ល្អ
៩៨	៩៨	សុខ ជា	ប្រុស	១២-១០-១៩៦៥	ល្អ
៩៩	៩៩	សុខ មករា	ប្រុស	១០-១-១៩៦៩	ល្អ

១០០	១០០	គង់ ចាន់ថន	ប្រុស	១២–១២–១៩៦៦	ល្អ
១០១	១០១	លឹម វិរក្ស	ប្រុស	១២–៤–១៩៦៦	ល្អ
១០២	១០២	នៅ ពន្លក	ប្រុស	១១–៥–១៩៧២	ល្អ
១០៣	១០៣	ម៉ង់ ហុងត្រី	ប្រុស	១១–១១–១៩៦៩	ល្អ
១០៤	១០៤	អ៊ុក វណ្ណដារ៉េត	ប្រុស	០១–៣–១៩៦៨	ល្អ
១០៥	១០៥	ប៊ុន លី	ប្រុស	១២–៦–១៩៦៥	ល្អ
១០៦	១០៦	ហោ សុខហោភ	ប្រុសុ	០៥–៥–១៩៧២	ល្អ
១០៧	១០៧	កែវ វណ្ណារិន	ប្រុស	០៩–៩–១៩៦៨	ល្អ
១០៨	១០៨	អ៊ុក រដ្ឋា	ស្រី	១១–១២–១៩៦៨	ល្អ
១០៩	១០៩	ចាប រដ្ឋមុនី	ប្រុស	២២–១១–១៩៧១	ល្អបង្គួរ
១១០	១១០	អ៊ី រតនៈ	ប្រុស	១២–១២–១៩៧២	ល្អបង្គួរ
១១១	១១១	រស់ ពេជ្រអមរិន្ទ	ប្រុស	២០–១២–១៩៧០	ល្អបង្គួរ
១១២	១១២	ជា សំអាត	ប្រុស	១៣–១–១៩៦៩	ល្អបង្គួរ
១១៣	១១៣	រ៉ិត ដារ៉ា	ប្រុស	០៥–៧–១៩៦៨	ល្អបង្គួរ
១១៤	១១៤	សួន តារា	ប្រុស	១២–៤–១៩៦៩	ល្អបង្គួរ
១១៥	១១៥	កែវ ស	ប្រុស	០១–១២–១៩៦៩	ល្អបង្គួរ
១១៦	១១៦	ផាត់ វ៉ាន់ធី	ប្រុស	០៣–១២–១៩៦៩	ល្អបង្គួរ
១១៧	១១៧	នួស្គា សត្យា	ប្រុស	១៩–៥–១៩៧០	ល្អបង្គួរ
១១៨	១១៨	សន ភីរម្យ	ប្រុស	២៧–៣–១៩៦៧	ល្អបង្គួរ
១១៩	១១៩	លឹម វាសនា	ប្រុស	១២–១២–១៩៦៩	ល្អបង្គួរ
១២០	១២០	អ៊ុក នរឫទ្ធិ	ប្រុស	១៦–១១–១៩៦៩	ល្អបង្គួរ
១២១	១២១	ម៉េង បុណ្ណារិទ្ធ	ប្រុស	១៥–១២–១៩៧១	ល្អបង្គួរ
១២២	១២២	តេក ឡុង	ប្រុស	០៧–៤–១៩៦៨	ល្អបង្គួរ
១២៣	១២៣	យឹម មុនី	ប្រុស	២៧–៥–១៩៦៩	ល្អបង្គួរ
១២៤	១២៤	ប៉េង សម្បត្តិ	ប្រុស	២០–១១–១៩៦៧	ល្អបង្គួរ

១២៥	១២៥	អ៊ឹង តារា	ប្រុស	០៥-៣-១៩៦៥	ល្អបង្គួរ
១២៦	១២៦	ង៉ែត សុផល	ប្រុស	១៤-១-១៩៦៦	ល្អបង្គួរ
១២៧	១២៧	សុខ ទីគុណា	ប្រុស	១២-៤-១៩៦៧	ល្អបង្គួរ
១២៨	១២៨	ភី ឈុនធី	ប្រុស	០២-១-១៩៧០	មធ្យម
១២៩	១២៩	ឃន សុត្ថារ៉ុង	ប្រុស	១៧-៨-១៩៦៤	មធ្យម
១៣០	១៣០	សេង ប៊ុនឡឿន	ប្រុស	១២-១២-១៩៦៧	មធ្យម
១៣១	១៣១	យ៉ន គឹមសេង	ប្រុស	១២-៣-១៩៦៥	មធ្យម
១៣២	១៣២	ជា សែ	ប្រុស	២១-១០-១៩៧០	មធ្យម
១៣៣	១៣៣	ធូ ពិសិដ្ឋ	ប្រុស	០៧-៨-១៩៦៩	មធ្យម
១៣៤	១៣៤	នាង សុជីវី	ប្រុស	១២-១០-១៩៧២	មធ្យម
១៣៥	១៣៥	ស៊ឹម ថន	ប្រុស	០២-៤-១៩៧០	មធ្យម
១៣៦	១៣៦	ចូវ សុខច័ន្ទ	ប្រុស	៣០-១២-១៩៥៥	មធ្យម

ប្រការ ២ : ខុទ្ទកាល័យ , អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ , សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ , អគ្គនាយកដ្ឋានគ្រប់គ្រង បេតិកភ័ណ្ឌ និងការពារវប្បធម៌ និងអគ្គនាយកដ្ឋានអភិវឌ្ឍន៍វប្បធម៌ និងវិចិត្រសិល្បៈ មានភារកិច្ចអនុវត្តប្រកាសនេះ ។

ប្រការ ៣ : ប្រកាសនេះមានប្រសិទ្ធិភាពចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
នុត ណារ៉ាង

* * *

៧_ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា

ប្រកាស

ភ្នំពេញ, ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ១៩៩៦

លេខ ៩៧៨ អយក.ប្រក

ស្តីពីការបើកវិទ្យាល័យសម្តេចឪ ក្នុងឃុំស្រង៉ែ ស្រុកសៀមរាប

ខេត្តសៀមរាប រដ្ឋមន្ត្រី ក្រសួងអប់រំយុវជន និងកីឡា

* * *

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ វិច្ឆិកា ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ កក្កដា ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ១២ឆ្នាំ
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទម ចុះថ្ងៃទី០២ ខែ មេសា ១៩៨៣ ស្តីពីការបើកសាលាមធ្យមសិក្សាកំរិត១-កំរិត២
- យោងលិខិតស្នើសុំរបស់មន្ទីរអប់រំយុវជន និងកីឡា ខេត្តសៀមរាប លេខ១០៣២ អយក.ខ ចទម ចុះថ្ងៃទី០៣ កញ្ញា ១៩៩៦ ដោយមានចំណារបញ្ជូនពីអភិបាល ខេត្តសៀមរាប
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា

សំរេច

ប្រការ១ : អនុញ្ញាតអោយមន្ទីរអប់រំយុវជន និងកីឡា ខេត្តសៀមរាប បើកវិទ្យាល័យ ដែលមានឈ្មោះថា **វិទ្យាល័យ សម្តេចឪ** ចាប់ពីឆ្នាំសិក្សា ១៩៩៦ - ៩៧ តទៅ ។

ប្រការ២ : វិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗមួយចំនួនទៀត តាមអង្គការលេខ នៃវិទ្យាល័យ ។

ប្រការ៣ : នាយក-នាយករង នៃវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចរបស់នាយក-នាយករងនៃវិទ្យាល័យ ។

ប្រការ៤ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផែនការ និងហិរញ្ញកិច្ច នៃក្រសួងអប់រំយុវជន និងកីឡា ប្រធានមន្ទីរអប់រំយុវជន និងកីឡា ខេត្តសៀមរាប និងនាយកវិទ្យាល័យសាមី មានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

រដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

តុល ឡោះ

* * *

ភ្នំពេញ,ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ១៩៩៦

ប្រកាស

លេខ ៩៧៩ អយក. ប្រក

ស្តីពីការប្តូរទីតាំងអនុវិទ្យាល័យបន្ទាយស្រី នៅ ខេត្តសៀមរាប

រដ្ឋមន្ត្រី ក្រសួងអប់រំយុវជន និងកីឡា

* * *

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ កក្កដា ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ១២ឆ្នាំ
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទម ចុះថ្ងៃទី០២ ខែ មេសា ១៩៨៣ ស្តីពីការបើកសាលាមធ្យមសិក្សាកំរិត១-កំរិត២

- យោងលិខិតស្នើសុំរបស់អភិបាលស្រុកបន្ទាយស្រី លេខ ២២៤/៨៦ សបល ចុះ ថ្ងៃទី១២ សីហា ១៩៨៦ ដោយមានចំណារបញ្ជូនពីមន្ទីរអប់រំយុវជន និងកីឡា និងអភិបាលខេត្ត សៀមរាប
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា

សំរេច

ប្រការ១ : អនុញ្ញាតអោយប្តូរទីតាំង អនុវិទ្យាល័យ បន្ទាយស្រី បច្ចុប្បន្ននៅទីតាំងថ្មី ក្នុងភូមិតាកុះ ឃុំព្រះដាក់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ប្រការ២ : អនុវិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំង បុគ្គលិកផ្សេងៗមួយចំនួនទៀត តាមអង្គការលេខ នៃអនុវិទ្យាល័យ ។

ប្រការ៣ : នាយក-នាយករង នៃអនុវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចរបស់នាយក-នាយករងនៃអនុវិទ្យាល័យ ។

ប្រការ៤ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ៥ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផែនការ និងហិរញ្ញកិច្ច នៃក្រសួងអប់រំយុវជន និងកីឡា ប្រធានមន្ទីរអប់រំយុវជន និងកីឡា ខេត្តសៀមរាប និងនាយកអនុវិទ្យាល័យសាមី មានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

រដ្ឋមន្ត្រី
ហត្ថលេខានិងត្រា
គុណ ឡោះ

* * *

ភ្នំពេញ,ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ១៩៩៦

ប្រកាស

លេខ ៩៨០ អយក.ប្រក

ស្តីពីការបើកអនុវិទ្យាល័យ ហ៊ុន សែន « ខ្នាកូន » ក្នុងឃុំកំពង់ស្វាយ

ស្រុកសិរីសោភ័ណ ខេត្ត បន្ទាយមានជ័យ

* * *

រដ្ឋមន្ត្រី ក្រសួងអប់រំយុវជន និងកីឡា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ កក្កដា ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ១២ឆ្នាំ
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទម ចុះថ្ងៃទី០២ ខែ មេសា ១៩៨៣ ស្តីពីការបើកសាលាមធ្យមសិក្សាកំរិត១-កំរិត២
- យោងលិខិតស្នើសុំរបស់មន្ទីរអប់រំយុវជន និងកីឡា ខេត្តបន្ទាយមានជ័យ លេខ ២៥០២ អយក.ខ មស ចុះ ថ្ងៃទី១០ កញ្ញា ១៩៩៦ ដោយមានយោបល់ឯកភាពពី អភិបាលខេត្តបន្ទាយមានជ័យ
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា

សំរេច

ប្រការ១ : អនុញ្ញាតអោយមន្ទីរអប់រំយុវជន និងកីឡាខេត្តបន្ទាយមានជ័យ បើកអនុវិទ្យាល័យ ដែលមានឈ្មោះថា អនុវិទ្យាល័យ ហ៊ុន សែន «ខ្នាកូន » ចាប់ពីឆ្នាំសិក្សា ១៩៩៦ -៩៧ តទៅ ។

ប្រការ២ : អនុវិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំង បុគ្គលិកផ្សេងៗមួយចំនួនទៀត តាមអង្គការលេខ នៃអនុវិទ្យាល័យ ។

ប្រការ៣ : នាយក-នាយករង នៃអនុវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចរបស់នាយក-នាយករងនៃអនុវិទ្យាល័យ ។

ប្រការ៤ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផែនការ និងហិរញ្ញកិច្ច នៃក្រសួងអប់រំយុវជន និងកីឡា ប្រធានមន្ទីរអប់រំយុវជន និងកីឡា ខេត្តសៀមរាប និងនាយកអនុវិទ្យាល័យសាមី មានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

រដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

តុល ឡោះ

* * *

ភ្នំពេញ,ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ១៩៩៦

ប្រកាស

លេខ ១០០០ អយក.ប្រក

ស្តីពីការបើកសាលាបឋមសិក្សា ហ៊ុន សែន ទាំងចាស់ ក្នុងឃុំទាំងចាស់ ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ

រដ្ឋមន្ត្រី ក្រសួងអប់រំយុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ កក្កដា ១៩៩៤

- បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេច សម្តេចព្រះនរោត្តម សីហនុ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា លេខ សន.រកត /០៧៩៦/៥២ ចុះថ្ងៃទី២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ១២ឆ្នាំ
- បានពិនិត្យលិខិតស្នើសុំរបស់មន្ទីរអប់រំ យុវជន និងកីឡា ខេត្តកំពង់ស្ពឺ លេខ ៦០៤ អយក ចុះថ្ងៃទី២៩ - ៨ - ៩៦
- តាមយោបល់ឯកភាព របស់នាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា

សំរេច

ប្រការ១ : អនុញ្ញាតអោយមន្ទីរអប់រំយុវជន និងកីឡា ខេត្តកំពង់ស្ពឺ បើកសាលា បឋមសិក្សាមួយកន្លែងមានឈ្មោះថា សាលាបឋមសិក្សា ហ៊ុន សែន វាំងចាស់ មានទីតាំងស្ថិតនៅក្នុងវត្ត វាំងចាស់ ឃុំវាំងចាស់ ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ចាប់ពីឆ្នាំ សិក្សា ១៩៩៦ - ៩៧ នេះតទៅ ។

ប្រការ២ : សាលាបឋមសិក្សាហ៊ុន សែន វាំងចាស់ ត្រូវដឹកនាំដោយនាយកមួយរូប ព្រមទាំងបុគ្គលិកផ្សេងៗសមស្របតាមបទដ្ឋានប្រើប្រាស់ក្របខណ្ឌសំរាប់សាលាបឋមសិក្សា ។

ប្រការ៣ : លោកនាយក មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍កំណត់របស់រដ្ឋ

ប្រការ៤ : បទបញ្ញតិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវទុកជានិរាករណ៍ ។

ប្រការ៥ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផែនការ និងហិរញ្ញកិច្ច ប្រធានមន្ទីរអប់រំយុវជន និងកីឡា ខេត្តកំពង់ស្ពឺ លោកប្រធានការិយាល័យអបរំយុវជន និងកីឡា ស្រុកឧដុង្គ លោក នាយកសាលាបឋមសិក្សា ហ៊ុន សែន វាំងចាស់ មានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ជ.រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា
រដ្ឋលេខាធិការ
ហត្ថលេខានិងត្រា
គា សាហាន

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ១៩៩៦

ប្រកាស

លេខ ១០០៥ អយក.ប្រក

ស្តីពីការប្តូរឈ្មោះអនុវិទ្យាល័យស្រយូវ ទៅជាអនុវិទ្យាល័យ ព្រះនរោត្តម រណឫទ្ធិ «ស្រយូវ» ស្ថិតក្នុងស្រុកស្ទឹងសែន ខេត្តកំពង់ធំ

* * *

រដ្ឋមន្ត្រី ក្រសួងអប់រំយុវជន និងកីឡា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ កក្កដា ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ១២ឆ្នាំ
- បានឃើញសារាចរណែនាំលេខ ៦៦ អ.ចទម ចុះថ្ងៃទី០២ ខែ មេសា ១៩៨៣ ស្តីពីការបើកសាលាមធ្យមសិក្សាកំរិត១-កំរិត២
- យោងលិខិតស្នើសុំរបស់គណៈកម្មការទ្រទ្រង់អនុវិទ្យាល័យស្រយូវ ចុះថ្ងៃទី០២ តុលា ១៩៩៦ ដោយមានចំណារបញ្ជូនពីមន្ទីរអប់រំយុវជន និងកីឡា និងអភិបាល ខេត្តកំពង់ធំ
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា

សំរេច

ប្រការ១ : អនុញ្ញាតអោយប្តូរឈ្មោះ អនុវិទ្យាល័យស្រយូវ ទៅជាអនុវិទ្យាល័យ ព្រះនរោត្តម រណឫទ្ធិ «ស្រយូវ» ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

ប្រការ២ : អនុវិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំង បុគ្គលិកផ្សេងៗទៀតមួយចំនួន តាមអង្គការលេខ នៃអនុវិទ្យាល័យ ។

ប្រការ៣ : នាយក-នាយករង នៃអនុវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចរបស់នាយក-នាយករងនៃអនុវិទ្យាល័យ ។

ប្រការ៤ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ៥ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផែនការ និងហិរញ្ញកិច្ច នៃក្រសួងអប់រំយុវជន និងកីឡា ប្រធានមន្ទីរអប់រំយុវជន និងកីឡា ខេត្តកំពង់ធំ និងនាយកអនុវិទ្យាល័យសាមី មានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ជ.រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា
រដ្ឋលេខាធិការ
ហត្ថលេខានិងត្រា
គា សាហាន

* * *

៨_ទីស្តីការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ១៩៩៦

ប្រកាស

លេខ ២០២ ទទ.ប្រក

ស្តីពីការតែងតាំងមន្ត្រីរាជការ

រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។

- បានឃើញព្រះរាជក្រមលេខ ០៦ នស ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ១៩៩៥
- បានឃើញព្រះរាជក្រម ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល លេខ០៦៥ ន.ល៩៤ ចុះថ្ងៃទី២១ ខែ តុលា ឆ្នាំ១៩៩៤
- បានឃើញព្រះរាជក្រម នស.រកម ០១៩៦-២០ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ប្រកាសអោយប្រើដោយច្បាប់ ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ១៩ កក្កដា ១៩៩៤ និងប្រកាសអោយប្រើនៅថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញសំណូមពររបស់នាយកដ្ឋានប្រៃសណីយ៍ និងពិនិត្យសមត្ថភាពមន្ត្រី បុគ្គលិករាជការ

សំរេច

ប្រការ១ : តែងតាំងមន្ត្រី បុគ្គលិក រាជការចំនួន០៦រូប នៅនាយកដ្ឋានប្រៃសណីយ៍ ដូចមានរាយនាមខាងក្រោមអោយទទួលតួនាទី និងភារកិច្ចនៅតាមការិយាល័យនីមួយៗ ដូចតទៅ :

១–លោក យស់ សុធា	អនុប្រធានការិ. ផែនការ-ហិរញ្ញកិច្ច នៃនាយកដ្ឋានប្រៃសណីយ៍
២–លោក ហ៊ូ ករុណា	អនុប្រធានការិ. ទូទាត់អន្តរជាតិនៃនាយកដ្ឋាន ប្រៃសណីយ៍
៣–លោក តោ គៀង	អនុប្រធានការិ. ប្រៃសណីយ៍ភ័ណ្ឌ នៃនាយកដ្ឋាន ប្រៃសណីយ៍
៤–លោក ចា សង្វាត	អនុប្រធានការិ. ប្រៃសណីយ៍ឆាប់រហ័ស នៃនាយកដ្ឋាន ប្រៃសណីយ៍
៥–លោក សុង ឡេង	អនុប្រធានការិ. តែមប្រិវិទ្យានៃនាយកដ្ឋាន ប្រៃសណីយ៍
៦–លោក ប្រាក់ សៀងអាន	អនុប្រធានការិ. បញ្ជូនសារទទួលបន្ទុកអនុសិដ្ឋចេញ នៃនាយកដ្ឋានប្រៃសណីយ៍

ប្រការ២ : មន្ត្រីរាជការចំនួន ០៦រូប ដូចមានចែងក្នុងប្រការ១ខាងលើ ត្រូវអនុវត្តតាមតួនាទីភារកិច្ច និងក្នុងសមត្ថកិច្ចរបស់ខ្លួន ។

ប្រការ៣ : ខុទ្ទកាល័យ អធិការដ្ឋាន នាយកដ្ឋានផែនការគណនេយ្យ-ហិរញ្ញកិច្ច នាយកដ្ឋានប្រៃសណីយ៍ និងសាមីខ្លួនទាំង០៦រូប ត្រូវទទួលបន្ទុកអនុវត្តន៍តាមខ្លឹមសារ នៃប្រកាសនេះ ។

ប្រការ៤ : ប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ហត្ថលេខានិងត្រា

សូ យុន

* * *

៩_ឧីស្តីការក្រសួងធម្មការ និងសាសនា

សេចក្តីសំរេច

ភ្នំពេញ,ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ១៩៩៦

សេចក្តីសំរេចលេខ ២៣៨/៩៦ កធស

អនុញ្ញាតជាគោលការណ៍អោយបង្កើតព្រះគ្រិស្តនិកាយប្រូតេស្តង់

ឈ្មោះ «បេសកកម្មសេចក្តីមេត្តាករុណា នៃព្រះគ្រិស្ត»

* * *

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី០១ខែ វិច្ឆិកា ឆ្នាំ១៩៩៣

- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និង សាសនា ដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ ន.ស.រ.ក.ម– ០១៩៦–១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញច្បាប់ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិលនៃ ព្រះរាជាណាចក្រកម្ពុជា លេខ : ០៦ ន.ស ១៩៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ : ២២ អនក្រ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩២ ដែលស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃក្រសួងធម្មការ និង សាសនា
- បានឃើញពាក្យសុំបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្តនិកាយប្រូតេស្តង់ឈ្មោះព្រះវិហារ " បេសកកម្មសេចក្តីមេត្តាករុណានៃព្រះគ្រិស្ត " ចុះថ្ងៃទី ២២ ខែ មេសា ឆ្នាំ ១៩៩៦ ព្រមទាំងមានចំណារបញ្ជូនរបស់ ឯកឧត្តមអភិបាលខេត្តពោធិសាត់ លេខ ៦៥៥ ព.ស ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៦

សំរេច

ប្រការ ១ : អនុញ្ញាតជាគោលការណ៍អោយបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្តនិកាយប្រូតេស្តង់ ឈ្មោះ " បេសកកម្មសេចក្តីមេត្តាករុណានៃព្រះគ្រិស្ត " មួយកន្លែង ដែលមានទីតាំងស្ថិតនៅ ភូមិមាន់ចៃ ឃុំព្រៃញី ស្រុកសំពៅមាស ខេត្តពោធិ៍សាត់

ប្រការ ២ : សាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្តខាងលើនេះ ត្រូវអនុញ្ញាតអោយផ្សព្វផ្សាយនូវរាល់ឯកសារផ្សេងៗ របស់លទ្ធិសាសនាគ្រិស្តដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

ប្រការ ៣ : បរិស័ទគ្រិស្តទាំងអស់របស់ស្នាក់ការនេះ ត្រូវគោរពអោយបានម៉ឺងម៉ាត់តាមច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា និង រាល់បទបញ្ញត្តិផ្សេងៗរបស់ក្រសួងធម្មការ និង សាសនា អ្នកដឹកនាំស្នាក់ការនេះ ត្រូវមានសាមគ្គីភាព និង ទំនាក់ទំនងអោយបានល្អជាមួយស្ថាប័នពាក់ព័ន្ធ សន្សាជាដាច់ខាត មិនធ្វើអោយប៉ះពាល់ដល់សិទ្ធិសេរីភាពខាងជំនឿសាសនា និង សណ្តាប់ធ្នាប់ របៀបរៀបរយសង្គម ។

ប្រការ ៤ : រាល់ការណ៍អនុវត្តន៍ផ្ទុយពី សេចក្តីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៥ : នាយកដ្ឋានសាសនា–មន្ទីរធម្មការ និង សាសនា ខេត្តពោធិសាត់ និង មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ដែលមានភារកិច្ចពាក់ព័ន្ធ ត្រូវសហការណ៍អនុវត្តន៍ សេចក្តីសំរេចនេះ អោយមានប្រសិទ្ធិភាព ។

ប្រការ ៦ : សេចកក្តីសំរេចនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

ហឿន វណ្ណរ័ត្ន

* * *

ភ្នំពេញ, ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ១៩៩៦

ប្រកាសលេខ : ២៦២/៩៦ ក.ធ.ស.ប្រក

ស្តីពីការប្រឡងសញ្ញាប័ត្រពុទ្ធិកមធ្យមសិក្សា

* * *

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រិត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- **បានឃើញព្រះរាជក្រមលេខ នស.រកម.០១៩៦–១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និង សាសនា**
- **បានឃើញច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា លេខ ០៦ នស ១៩៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤**
- **បានឃើញអនុក្រិត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩២ ដែលរៀបចំ និង ប្រព្រឹត្តទៅ នៃក្រសួងធម្មការ និង សាសនា**
- យោងលិខិតអនុញ្ញាតអោយបើកពុទ្ធិកមធ្យមសិក្សា លេខ ២០០២ សជណ.ផលផក ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ១៩៩២
- បានឃើញការចាំបាច់នៃក្រសួង

សំរេច

ប្រការ ១ : អនុញ្ញាតអោយអគ្គាធិការដ្ឋានពុទ្ធិកសិក្សា រៀបចំការប្រឡងសញ្ញាប័ត្រពុទ្ធិកមធ្យមសិក្សា ចាប់តាំងពីឆ្នាំសិក្សា ១៩៩៦–១៩៩៧ តទៅរៀងរាល់ឆ្នាំ ។

ប្រការ ២ : សមណសិស្សទាំងឡាយណាដែលបានរៀនចប់ថ្នាក់ឆ្នាំទី ៤ នៃគ្រឹះស្ថានពុទ្ធិកមធ្យមសិក្សា មានសិទ្ធិដាក់ពាក្យសុំប្រឡងយកសញ្ញាប័ត្រពុទ្ធិកមធ្យមសិក្សា ។

ប្រការ ៣ : ការប្រឡងសញ្ញាប័ត្រពុទ្ធិកមធ្យមសិក្សា ត្រូវកំណត់ធ្វើជាពីរលើកក្នុងមួយឆ្នាំគឺ លើកទី ១ និង លើកទី ២ ។

ប្រការ ៤ : ការប្រឡងសញ្ញាប័ត្រពុទ្ធិកមធ្យមសិក្សា ត្រូវចាត់ចែងឡើងដោយគណៈកម្មការមួយដែលតែងតាំងឡើងដោយរដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា ។ សមាសភាពមាន :

–រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា ឬ តំណាង ប្រធាន

–អគ្គាធិការពុទ្ធិកសិក្សា អនុប្រធាន

–តំណាងសម្តេចសង្ឃរាជទាំងពីរគណៈ សមាជិក

–នាយកពុទ្ធិកវិទ្យាល័យ សមាជិក

–សាស្ត្រាចារ្យ មន្ត្រីរាជការក្រសួងធម្មការ សមាជិក ។

ប្រការ ៥ : ការប្រឡងសញ្ញាប័ត្រពុទ្ធិកមធ្យមសិក្សាមានវិញ្ញាសាសរសេរ ។ ប្រធានវិញ្ញាសានីមួយៗ ត្រូវជ្រើសរើសដោយប្រធានគណៈមេប្រយោគ ។ វិញ្ញាសានីមួយៗ ត្រូវដាក់ក្នុងស្រោមសំបុត្របិទជិតបោះត្រាក្រសួង ហើយត្រូវបើកនៅចំពោះមុខបេក្ខសមណៈក្នុងថ្នាក់ណាមួយជាកំហិត ។

ប្រការ ៦ : វិញ្ញាសាសរសេរប្រឡងសញ្ញាប័ត្រពុទ្ធិកមធ្យមសិក្សាមាន :

វិញ្ញាសា	រយៈពេល	មេគុណ
១–ប្រែបាលីជាខ្មែរ ឬ ពីខ្មែរទៅបាលី	២ h ០០	០៣
២–ប្រែពីសំស្ក្រឹតជាខ្មែរ ឬ ពីខ្មែរទៅសំស្ក្រឹត	១ h ៣០	០២
៣–ប្រែពីអង់គ្លេសជាខ្មែរ ឬ ពីខ្មែរទៅអង់គ្លេស	១ h ៣០	០២
៤–អធិប្បាយអំពី អភិធម្មឬវិន័យ	២ h ០០	០៣

៥–តែងសេចក្តីខ្មែរ	២ h 00	0២
៦–គណិតវិទ្យា	២ h 00	0២
៧–រូបវិទ្យា–គីមីវិទ្យា	២ h 00	0២
៨–ប្រវត្តិសាស្ត្រ–ភូមិសាស្ត្រ	២ h 00	0១
៩–ជីវវិទ្យា	១ h 00	0១

ប្រការ ៧ : ពិន្ទុសំរាប់វិញ្ញាសានីមួយៗ ត្រូវកំណត់ពី ០ ដល់ ២០ ។ វិញ្ញាសាណាមួយដែលសូន្យ ត្រូវចាត់ទុកថាធ្លាក់ ។ គណៈកម្មការត្រូវធ្វើបញ្ជីរាយនាម និងពិន្ទុរបស់បេក្ខសមណៈមួយរូបៗ ដែលប្រឡងជាប់ទៅសុំការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា ។ បេក្ខសមណៈដែលបានពិន្ទុទាំងអស់ ១៨០ ឬ លើសពីនេះ ត្រូវចាត់ទុកថាបានប្រឡងជាប់ ។

ប្រការ ៨ : ការចុះនិទ្ទេសតាមចំនួនពិន្ទុមានដូចតទៅ ÷

–ពិន្ទុពី ១៨០ ដល់ ២២០ និទ្ទេស មធ្យម

–ពិន្ទុពី ២២០, ២៥ ដល់ ២៧០ និទ្ទេស ល្អបង្គួរ

–ពិន្ទុពី ២៧០, ២៥ ដល់ ៣០៦ និទ្ទេស ល្អ

–ពិន្ទុពី ៣០៦,២៥ ឡើងទៅ និទ្ទេស ល្អណាស់

ប្រការ ៩ : នាយកខុទ្ទកាល័យ អគ្គាធិការដ្ឋានពុទ្ធកសិក្សា ប្រធាននាយកដ្ឋានរដ្ឋបាល ផែនការហិរញ្ញកិច្ច ប្រធាននាយកដ្ឋានដែលពាក់ព័ន្ធមានភារកិច្ចអនុវត្តប្រកាសនេះ អោយមានប្រសិទ្ធភាពខ្ពស់ ។

ប្រការ ១០: ប្រកាសនេះ មាននប្រសិទ្ធិភាពចាប់តាំងពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិកា

ហត្ថលេខា និងត្រា

ហៀង ឧណ្ណារ័ត្ន

* * *

បោះពុម្ពនៅរោងពុម្ព ទីស្តីការគណៈរដ្ឋមន្ត្រី
លើកទី១ ចំនួន ៨០០ ច្បាប់

តម្លៃ ២០០០ រៀល